លេខៈ ធ៧-០០-៥១ ប្រក

# ប្រកាស

## ស្តីពី

## ចំណាត់ថ្នាក់និងសំវិធានធនលើបំណុលអាក្រក់
## និងបំណុលសង្ស័យរួមទាំងការប្រាក់ដែលបានព្យួរ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រិត្យលេខ ជស/ រកត / ០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

## សំ រេ ច

**ប្រការ ១.-**

ធនាគារត្រូវរៀបចំប្រព័ន្ធពតិមានគណនេយ្យផ្ទៃក្នុងរបស់ខ្លួន ដើម្បីអាចមានលទ្ធភាពផ្តល់ជាអចិន្ត្រៃយ៍ជូនធនាគារជាតិនៃកម្ពុជា នូវពតិមានស្របតាមបញ្ញត្តិនៃប្រកាសនេះ ។

**ប្រការ ២ .-**

ធនាគារត្រូវធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មរបស់ខ្លួន ជាពិសេសសំណុំឥណទាន(loan portfolio) ចំពោះអតិថិជនគ្រប់ប្រភេទ ( ធនាគារ ឯកត្តជន ក្រុមហ៊ុនអាជីវកម្ម និងអង្គភាពរដ្ឋាភិបាល ) និងការសន្យាក្រៅតារាងតុល្យការរបស់ខ្លួន ជា ៤ ថ្នាក់ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ។

**ប្រការ ៣ ៈ**

រាល់ទ្រព្យសកម្មនិងការសន្យាដែលស្ថិតក្នុងចំណាត់ថ្នាក់បំណុលក្រោមស្តង់ដារ បំណុលសង្ស័យនិងបំណុលបាត់បង់ ត្រូវតែបានកត់ត្រាក្នុងខ្ទង់ដែលពាក់ព័ន្ធ ។ ចំណាត់ថ្នាក់ទាំងនេះត្រូវតែបញ្ចូលទៅក្នុងរបាយការណ៍តាមការតំរូវរបស់ធនាគារជាតិនៃកម្ពុជា ជាពិសេសលើរបាយការណ៍ប្រចាំខែស្តីពីទ្រព្យសកម្មនិងខ្ទង់ក្រៅតារាងតុល្យការ ។

**ប្រការ ៤ ៈ**

យោលទៅតាមចំណាត់ថ្នាក់ដែលបានធ្វើ កំរិតអប្បបរមានៃការធ្វើសំវិធានធន ត្រូវមានដូចខាងក្រោមនេះ ដោយមិនគិតដល់ទ្រព្យសកម្មដែលបានរក្សាទុកជាទ្រព្យសំរាប់ធានា (លើកលែងតែសាច់ប្រាក់) ÷

- បំណុលក្រោមស្តង់ដារ : ម្ភៃភាគរយ (20 %)
- បំណុលសង្ស័យ : ហាសិបភាគរយ (50 %)
- បំណុលបាត់បង់ : មួយរយភាគរយ (100 %) ។

**ប្រការ ៥ ៈ**

ការធ្វើសំវិធានធនណាមួយ ( specific provision ) ត្រូវបានកត់ត្រានៅក្នុងគណនីរបស់ធនាគារ ហើយត្រូវបានដកចេញពីគណនីចំណេញខាតនៅក្នុងខែដែលត្រូវធ្វើសំវិធានធននេះ ។ សំវិធានធនមិនអាចពន្យារទៅគ្រាបន្ទាប់ទៀតទេ ។ នៅពេលណាដែលសមតុល្យគណនីរបស់អតិថិជនមានបញ្ចូលការប្រាក់ ក្នុងនោះគណនីបដិភាគត្រូវបានកត់ត្រាជាការប្រាក់ព្យួរ ( មើលប្រការ ៦ ខាងក្រោម ) ចំនួនប្រាក់នេះមិនត្រូវយកមកគិតសំរាប់គណនាសំវិធានធនទេ ។

**ប្រការ ៦ ៈ**

ស្របតាមមូលដ្ឋានបង្គរនៃគណនេយ្យ (accrual basis accounting) ការប្រាក់បង្គរលើគណនីអតិថិជន ត្រូវបានកត់ត្រាជាចំណូលក្នុងគណនីចំណេញខាត ។ ប៉ុន្តែ មិនត្រូវអនុវត្តតាមទំរង់ការបែបនេះទេ ចំពោះទ្រព្យសកម្មទាំងឡាយណាដែលត្រូវបានចាត់ថ្នាក់ជាបំណុលក្រោមស្តង់ដារ បំណុលសង្ស័យ ឬបំណុលបាត់បង់ ។ ក្នុងស្ថានភាពនេះ ការប្រាក់បង្គរត្រូវកត់ត្រាខាងឥណទាននៃគណនីសំរាប់ការប្រាក់ព្យួរ ។

**ប្រការ ៧ ._**

ការរំលោភលើបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងនូវទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៨ ._**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩ ._**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ១០ ._**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០០

**ទេសាភិបាល**

**<u>កន្លែងទទួល</u>**

- ដូចប្រការ ៩
  " ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

<u>cmøgCUn</u>

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាពតិមាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

## ឧបសម្ព័ន្ធនៃប្រកាសស្តីពីចំណាត់ថ្នាក់និងសំវិធានធន
## លើបំណុលអាក្រក់និងបំណុលសង្ស័យ រួមទាំងការប្រាក់ដែលបានព្យួរ

### ចំណាត់ថ្នាក់ឥណទាន

| លក្ខណៈវិនិច្ឆ័យ | ដំណើរការសងប្រាក់ | ស្ថានភាពហិរញ្ញវត្ថុ |
|---|---|---|
| **បំណុលស្តង់ដារ**<br>- ទ្រព្យសកម្មដំណើរការ<br>...................................................<br>- ទ្រព្យសកម្មមិនដំណើរការ<br>...................................................<br>- ទ្រព្យសកម្មមានការធានាពេញលេញ (ប្រាក់ដើមនិងការប្រាក់ ដោយសាច់ប្រាក់ និងជំនួសសាច់ប្រាក់) | - ទៀងពេល<br>...................................................<br>- ហួសកាលកំណត់ > ៣០ថ្ងៃ<br>...................................................<br>- អាចមានការលំបាកផ្សេងៗ ក្នុងសេវា | - ស្ថានភាពហិរញ្ញវត្ថុល្អបំផុត<br>...................................................<br>- ស្ថានភាពហិរញ្ញវត្ថុល្អ<br>...................................................<br>- បង្ហាញនូវចំណុចខ្សោយផ្នែកហិរញ្ញវត្ថុ |
| **បំណុលក្រោមស្តង់ដារ** | ហួសកាលកំណត់ > ៩០ថ្ងៃ<br>- បុរេប្រទានលើសកំរិតឥណទាន ៩០ថ្ងៃ ឬច្រើនជាង<br>- ប្រាក់បញ្ញើលើគណនី < ការប្រាក់ដល់កាលកំណត់ ៩០ថ្ងៃ | ទ្រព្យសកម្មមិនត្រូវបានការពារពេញលេញតទៅទៀត ដោយស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុល ដែលអាចមានការលំបាកក្នុងការសងបំណុល |
| **បំណុលសង្ស័យ** | ហួសកាលកំណត់ > ១៨០ថ្ងៃ<br>- បុរេប្រទានលើសកំរិតឥណទាន ១៨០ថ្ងៃ ឬច្រើនជាង<br>- ប្រាក់បញ្ញើលើគណនី < ការប្រាក់ដល់កាលកំណត់ ១៨០ថ្ងៃ | ចំណុចខ្សោយបច្ចុប្បន្ននិងអនាគតរបស់កូនបំណុលធ្វើឱ្យការសងបំណុលគ្រប់ចំនួនត្រូវមានការសង្ស័យឬមិនអាចសងបាន។ លទ្ធភាពនៃការខាតបង់ខ្ពស់ ប៉ុន្តែកត្តាពិសេសចំនួនដែលអាចបង្កើនកំលាំងទ្រព្យសកម្មអាចអនុញ្ញាតអោយពន្យារការធ្វើចំណាត់ថ្នាក់ជាការខាតបង់។ |
| **បំណុលបាត់បង់** | ហួសកាលកំណត់ > ៣៦០ថ្ងៃ<br>- បុរេប្រទានលើសកំរិតឥណទាន ៣៦០ថ្ងៃ ឬច្រើនជាង<br>- ប្រាក់បញ្ញើលើគណនី < ការប្រាក់ដល់កាលកំណត់ ៣៦០ថ្ងៃ | ទ្រព្យសកម្មដែលត្រូវបានធ្វើចំណាត់ថ្នាក់ជាខាតបង់សន្មត់ថា មិនអាចប្រមូលបាន តែបើបានវិញក៏ស្តួចស្តើង |

**កំណត់សំគាល់ :**

១- ចំណាត់ថ្នាក់ត្រូវធ្វើលើរាល់ឥណទានដោយផ្ទាល់ និងប្រយោល ដោយគិតទាំងឱ្យខ្ចី គណនីលើសសមតុល្យ ទ្រព្យសម្បត្តិដែលរឹបអូសបានដោយសារកិច្ចសន្យាបំណុលពីមុន ការវិនិយោគ ភាគកម្ម និងការសន្យាក្រៅតារាងតុល្យការ ( លិខិតឥណទាន លិខិតធានា ។ល។ )

២- ឥណទាននិងបុរេប្រទានដែលបានរៀបចំឡើងវិញ គឺជាឥណទានដែលបានធ្វើបុនហិរញ្ញប្បទាន ធ្វើកាលវិភាគថ្មី ផ្តល់សារឡើងវិញ ឬបានកែប្រែកាលកំណត់និងលក្ខខ័ណ្ឌសមស្របនឹងអ្នកខ្ចី ព្រោះតែចំណុចខ្សោយលើស្ថានភាពហិរញ្ញវត្ថុ ឬលទ្ធភាពសងបំណុលក៏ដោយ ការរៀបចំឡើងវិញមិនអាចនាំទៅដល់ការធ្វើអោយប្រសើរឡើង លើកលែងតែមានភស្តុតាងរឹងមាំនៃការរីកចំរើននូវស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន ។